ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះ
ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល
នីតិកាលទី៧នៃរដ្ឋសភា (គ.វ.រ.)

# ផែនការសកម្មភាព ២០២៤ - ២០២៨
# ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ
# របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

ក្រសួងមុខងារសាធារណៈ
លេខាធិការដ្ឋាននៃ គ.វ.រ.

ឆ្នាំ២០២៤

# បុព្វកថា

ក្រោមម្លប់សុខសន្តិភាព រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា បាននិងកំពុងបន្តការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍប្រទេសជាតិ និងការងារកែទម្រង់សំខាន់ៗក្នុងគោលដៅបម្រើឧត្តមប្រយោជន៍ជាតិ និងឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាជន។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាក្នុងឆ្នាំ២០៣០ ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសដែលមានចំណូលខ្ពស់។

នៅក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាពចំនួន៦ បន្ថែមទៀត រួមមាន ១).ការពង្រីកសេវាថៃទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ២).ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសជូនដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ដែលមានចំនួនសរុបប្រមាណ ១.៥លាននាក់ ដោយរាជរដ្ឋាភិបាលទទួលបន្ទុករ៉ាប់រងលើថ្លៃសិក្សា និងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ៣).ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានគ្រោះអាសន្ន ៤).ការដាក់ចេញយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ ៥).ការដាក់ចេញនូវយន្តការសម្រុះសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ និង៦).ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មនៅឃុំ សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស និងការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ។

ទន្ទឹមនេះ រាជរដ្ឋាភិបាល បានដាក់ចេញនូវវិធានការគន្លឹះសំខាន់ៗទៅតាមវិស័យអាទិភាព និងរៀបចំបង្កើតនូវយន្តការអនុវត្ត ដើម្បីដោះស្រាយបញ្ហាប្រឈម និងការធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងការឆ្លើយតបទាន់ពេលវេលាទៅនឹងគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ចំនួន ៣ ក្នុងនោះរួមមានៈ **(១)**.គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដើម្បីលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាព និងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ តាមរយៈ ទី១.ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន ទី២.ការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពការងារប្រកបដោយវិន័យ សីលធម៌ និងវិជ្ជាជីវៈ និងទី៣.ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព **(២)**. គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.អ.) ដើម្បីលើកកម្ពស់គុណភាពអប់រំ តាមរយៈការពង្រឹងគុណភាពសាលារៀន ចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា សម្រាប់ផលិតមូលធនមនុស្សប្រកបដោយចំណេះដឹង និងជំនាញ សីលធម៌ល្អ ឥរិយាបថល្អ និងសមត្ថភាពបំពេញការងារខ្ពស់ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គមសេដ្ឋកិច្ច និងទីផ្សារការងារ និង**(៣)**.គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.ស.) ដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជនតាមរយៈការពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន។

ជាមួយគ្នានេះ ក្រសួងមុខងារសាធារណៈ ត្រូវដើរតួនាទីយ៉ាងសកម្មក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលទាមទារឱ្យមានការរៀបចំដាក់ចេញនូវផែនការសកម្មភាពជាក់លាក់សម្រាប់ការអនុវត្តក្នុងរយៈពេលចាប់ពីឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៨។ ការរៀបចំផែនការសកម្មភាព ត្រូវគិតគូរក្នុងក្របខណ្ឌអនុវត្តឱ្យមានភាពប្រទាក់ក្រឡា គាំទ្រគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក ពិសេស ត្រូវលើកកម្ពស់ការចូលរួមពីគ្រប់តួអង្គទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត ដោយឈរលើអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**"។

ផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ជាផ្នែកមួយដ៏សំខាន់ដែលនឹងរួមចំណែកក្នុងការសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ឱ្យទទួលបានភាពជោគជ័យ។ ផែនការសកម្មភាពនេះផ្តោតជាអាទិភាពលើ៖ ទី១.ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ទី២.ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព និង ទី៣.ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

ក្នុងក្របខណ្ឌនៃការអនុវត្តផែនការសកម្មភាព ២០២៤-២០២៨ នេះ ក្រសួងមុខងារសាធារណៈ ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តប្រកបដោយភាពបុរេសកម្ម សកម្ម និងនវានុវត្តន៍។ ទន្ទឹមនេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ និងតួអង្គពាក់ព័ន្ធផ្សេងទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវចូលរួមសហការ គាំទ្រ និងអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលតាមការរំពឹងទុក។

ផ្អែកលើការគាំទ្រ និងការចូលរួមអនុវត្តដ៏សកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងតួអង្គពាក់ព័ន្ធទាំងអស់ ខ្ញុំសង្ឃឹមថា កម្ពុជានឹងបោះជំហានទៅមុខប្រកបដោយភាពស្វាហាប់ ដើម្បីសម្រេចបាននូវការកសាងរដ្ឋបាលសាធារណៈទំនើប ដែលមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ សំដៅគាំទ្រដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ឈរលើគោលការណ៍នៃសមធម៌ យុត្តិធម៌សង្គម និងបរិយាបន្ន។

ថ្ងៃ សុក្រ ២រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# អារម្ភកថា

ការងារកែទម្រង់រដ្ឋបាលសាធារណៈ គឺមិនមែនជាកិច្ចការងារថ្មីនោះទេ តែជាកិច្ចការងារដែលទាមទារឱ្យធ្វើជាប់ជាប្រចាំ កាន់តែសកម្ម កាន់តែលម្អិត ស្របតាមផែនការជាក់លាក់ ទើបនាំឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ស្របតាមប្រសាសន៍ដ៏ខ្លង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលថា កិច្ចការកែទម្រង់ ត្រូវមានចក្ខុវិស័យច្បាស់លាស់ ការប្តេជ្ញាចិត្តខ្ពស់ ការចូលរួម ដោយស្មោះត្រង់ និងការលះបង់។

នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយបន្តផ្តោតលើអាទិភាពគន្លឹះចំនួន៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា** ដែលមានស្នូលផ្តោតលើ "**ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច**"។ ទន្ទឹមនេះ ក្រសួងមុខងារសាធារណៈ ដែលជាសេនាធិការជូនរាជរដ្ឋាភិបាល ត្រូវគ្រប់គ្រងដឹកនាំវិស័យមុខងារសាធារណៈ និងការងារកែទម្រង់រដ្ឋបាលសាធារណៈ សំដៅឈានទៅធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ និងបង្កើនជំនឿទុកចិត្តពីប្រជាជន។

ក្រោមការចង្អុលបង្ហាញប្រកបដោយចក្ខុវិស័យរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងមុខងារសាធារណៈ ក្នុងនាមជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា មានភារកិច្ចចម្បងជានាការអនុវត្តការងារសារវន្តចំនួន៣ ដើម្បីលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាព និងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ តាមរយៈ ១).ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ២).ការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ និង៣).ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ។

ឈរលើមូលដ្ឋាននេះ ក្រសួងមុខងារសាធារណៈ បានរៀបចំផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលមានការពាក់ព័ន្ធផ្ទាល់ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់នូវសកម្មភាព អាទិភាព ក្របខណ្ឌពេលវេលា សូចនាករសមិទ្ធកម្ម យន្តការអនុវត្ត និងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

ផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានរៀបចំឡើងដោយផ្អែកលើវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ព្រមទាំងបានគិតគូរដល់ការផ្សារភ្ជាប់នូវគោលបំណង និងសកម្មភាព ជាមួយនឹងគោលនយោបាយ និងកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល ព្រមទាំងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ផែនការសកម្មភាពនេះ ត្រូវបានរៀបចំ និងឆ្លងកាត់កិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើកក្នុងកម្រិតបច្ចេកទេសនិងកម្រិតនយោបាយនៅក្នុងក្រសួងមុខងារសាធារណៈ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជានាសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយសម្រាប់ការអនុវត្ត។ ជាចុងក្រោយ ផែនការសកម្មភាពនេះ ត្រូវបាន

ដាក់ឆ្លងកិច្ចប្រជុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា មុននឹងគោរពស្នើសុំការពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល និងជាប្រធានគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.រ.)។

ក្រសួងមុខងារសាធារណៈ ក្នុងនាមជាលេខាធិការដ្ឋាននៃ គ.វ.រ. នឹងប្ដេជ្ញាយកអស់កម្លាំងកាយចិត្ត និងបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ដោយសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់តួអង្គពាក់ព័ន្ធ ក្នុងការជំរុញការអនុវត្តផែនការសកម្មភាពដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ឱ្យទទួលបានភាពជោគជ័យ ស្របតាមចក្ខុវិស័យវែងឆ្ងាយ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ថ្ងៃ ព្រហស្បតិ៍ ១៣កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាអនុប្រធានប្រចាំការនៃ គ.វ.រ.**

**ហ៊ុន ម៉ានី**

## មាតិកា

**បុព្វកថា** ............ i

**អារម្ភកថា** ............ iii

**១.សារធាតុ** ............ ១

**២.យុទ្ធសាស្ត្រ** ............ ២

**៣.ផែនការសកម្មភាព** ............ ៣

៣.១.វិធានការគន្លឹះទី១៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ............ ៣

៣.២.វិធានការគន្លឹះទី២៖ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ............ ៣

៣.៣.វិធានការគន្លឹះទី៣៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព ............ ៤

**៤.យន្តការស្ថាប័នទទួលបន្ទុកអនុវត្តសកម្មភាព** ............ ៤

៤.១.យន្តការអនុវត្តក្នុងក្របខណ្ឌលេខាធិការដ្ឋាននៃ គ.វ.វ. ............ ៤

៤.២.យន្តការអនុវត្តក្នុងក្របខណ្ឌនៃអន្តរ-លេខាធិការដ្ឋាននៃការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ............ ៧

**៥.ធនធានគាំទ្រការអនុវត្តសកម្មភាព** ............ ៧

**៦.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ** ............ ៨

**៧.សេចក្តីសន្និដ្ឋាន** ............ ៨

**ឧបសម្ព័ន្ធ៖ ផែនការសកម្មភាពអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា** ............ ១០

## ១.សារបាន

គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា **(គ.វ.រ.)** មាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធាន ព្រមទាំងមានឧបនាយករដ្ឋមន្ត្រី ជាអនុប្រធាន និងរដ្ឋមន្ត្រីនៃក្រសួង រដ្ឋលេខាធិការដ្ឋាន និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាសមាជិក ក្នុងនោះ ក្រសួងមុខងារសាធារណៈ ដើរតួនាទីជាលេខាធិការដ្ឋាននៃ គ.វ.រ.។

គ.វ.រ. មានសមត្ថកិច្ចក្នុងការដឹកនាំ និងជំរុញការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ តាមរយៈការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ដែលជាវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ក្នុងក្របខណ្ឌនៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ឱ្យឆ្លើយតបទៅនឹងវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ពាក់ព័ន្ធទៅនឹងការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈកម្ពុជា តម្រូវឱ្យមានការពិនិត្យមើលទៅលើស្ថានភាពសំខាន់ៗដូចខាងក្រោម៖

### ទី១. ស្ថានភាពអំពីដំណើរការនៃការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា

- ដំណើរការនៃការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំ និងគ្រប់គ្រងដោយក្រសួង ស្ថាប័នផ្សេងៗគ្នា ដែលនាំឱ្យមានចំណោទអំពីប្រសិទ្ធភាពនៃដំណើរការក្នុងប្រព័ន្ធនៃការជ្រើសរើស
- បែបបទ និងនីតិវិធីនៃការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា មិនទាន់មានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាបាននូវដំណើរការនៃការជ្រើសរើសប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងឆ្លើយតបនឹងស្ថានភាពជាក់ស្តែងនៃប្រភេទការងារ
- ការរៀបចំផែនការនៃការជ្រើសរើសប្រចាំឆ្នាំ មិនទាន់ឆ្លើយតបពិតប្រាកដនឹងសេចក្តីត្រូវការ និងប្រភេទនៃការងារ។ បន្ទាប់ពីការជ្រើសរើស និងការបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការ ការផ្លាស់ប្តូរកន្លែងការងារ និងប្រភេទការងាររបស់មន្ត្រីតែងតែកើតមានឡើង ដែលនាំឱ្យមានស្ថានភាពលើសមន្ត្រី ឬ ខ្វះមន្ត្រីកើតឡើងជាប្រចាំក្នុងរដ្ឋបាលសាធារណៈ
- ការគ្រោងថវិកាសម្រាប់បន្ទុកបុគ្គលិក និងការជ្រើសរើសមន្ត្រី មិនទាន់មានភាពប្រទាក់ក្រឡាគ្នា នាំឱ្យមានករណីមួយចំនួនកើតឡើងដូចជា៖ ១).ការជ្រើសរើសមន្ត្រីមិនត្រូវបានអនុវត្តផ្អែកលើ

ផែនការក្របខណ្ឌនិងពេលវេលាជាក់លាក់ និង ២).បន្ទុកបុគ្គលិក ត្រូវបានកត់សម្គាល់ឃើញថា មានការកើនឡើងជាលំដាប់។

**ទី២. ស្ថានភាពអំពីការបំពេញការងាររបស់មន្ត្រីរាជការក្នុងពេលបច្ចុប្បន្ន**

- ការប្រកាន់ខ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលស្គាល់តម្លៃសាធារណៈក្នុងមុខងារនៅមានកម្រិត
- ប្រព័ន្ធការងារ និងបែបបទនៃការបំពេញការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមានលក្ខណៈមជ្ឈការកម្រិតខ្ពស់
- ការបែងចែកការងារ ការកំណត់ប្រភេទការងារ វិសាលភាពការងារ ការកំណត់អំពីកម្រិតនៃការទទួលខុសត្រូវ គណនេយ្យភាព និងសមិទ្ធកម្ម នៅមិនទាន់មានការរៀបចំពេញលេញ និងជាប្រព័ន្ធការងារច្បាស់លាស់ ប្រទាក់ក្រឡា និងគាំទ្រគ្នានៅឡើយ
- ការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន រួមទាំងការអនុវត្តការគ្រប់គ្រងវិន័យការងារប្រកបដោយភាពម៉ឺងម៉ាត់ និងហ្មត់ចត់ នៅមានកម្រិត
- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈជាប្រព័ន្ធមិនទាន់អនុវត្តប្រកបដោយប្រសិទ្ធភាព។

**ទី៣. ស្ថានភាពអំពីការអនុវត្តការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ឬ របបឧបត្ថម្ភបន្ថែម**

- ការលើកទឹកចិត្តទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ចំពោះការបំពេញការងាររបស់មន្ត្រីអនុវត្តបានដោយផ្នែក និងមិនទាន់អនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់
- ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត មិនត្រូវបានអនុវត្តជាប្រព័ន្ធទូទៅនៅក្នុងរដ្ឋបាលសាធារណៈ ដែលចោទជាបញ្ហាអំពីសមធម៌ និងសង្គតិភាពនៃវិធានការគាំទ្រ និងលើកទឹកចិត្តដល់មន្ត្រី និងអង្គភាព
- ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តមិនទាន់ឆ្លើយតបទៅនឹងសមិទ្ធកម្ម ព្រមទាំងមិនអាចទាក់ទាញ និងរក្សាអ្នកដែលមានសមត្ថភាពខ្ពស់សម្រាប់បំពេញការងារក្នុងរដ្ឋបាលសាធារណៈ
- ការអនុវត្តការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត និងរបបឧបត្ថម្ភបន្ថែម មិនមានក្របខណ្ឌគតិយុត្តរួមរបស់រាជរដ្ឋាភិបាល ដែលអាចធានាបាននូវភាពច្បាស់លាស់ សង្គតិភាព សុខដុមនីយកម្ម និងប្រសិទ្ធភាព
- ការផ្តល់អត្ថប្រយោជន៍បន្ថែមផ្នែកហិរញ្ញវត្ថុដល់មន្ត្រី មិនត្រូវបានគិតគូរដោយផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយនៃការដំឡើងបៀវត្សជាទូទៅរបស់មន្ត្រីរាជការ ដែលនាំឱ្យគម្លាតនៃផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់មន្ត្រី និងបន្ទុកចំណាយក៏មានកើនឡើងជាលំដាប់ រហូតឈានដល់ការផ្តល់ការលំបាកក្នុងការគ្រប់គ្រង។

## ២.យុទ្ធសាស្ត្រ

ផ្អែកលើស្ថានភាពខាងលើនេះ ការគិតគូរ និងការដោះស្រាយក្នុងក្របខណ្ឌជាយុទ្ធសាស្ត្រ ត្រូវរៀបចំ និងដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ចំនួន៣ ដូចខាងក្រោម៖

- ➢ វិធានការគន្លឹះទី១ ៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព
- ➢ វិធានការគន្លឹះទី២ ៖ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាព ការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- ➢ វិធានការគន្លឹះទី៣៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយ សង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

## ៣.ផែនការសកម្មភាព

ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ឱ្យឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ និង ផែនការសកម្មភាពគន្លឹះ ត្រូវបានរៀបចំ និងដាក់ចេញ ដូចខាងក្រោម៖

### ៣.១.វិធានការគន្លឹះទី១៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ផ្តើមចេញពីការកត់សម្គាល់នូវស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងមន្ត្រី បញ្ហាប្រឈម និងការគិតគូរអំពីវិធានការដើម្បីកែលម្អប្រព័ន្ធនៃការជ្រើសរើសមន្ត្រី សំដៅជានាឱ្យបាន *“ជាប់ដោយមោទនភាព ធ្លាក់ដោយអស់ចិត្ត”*។

ដើម្បីសម្រេចបាននូវវិធានការគន្លឹះទី១ ចង្កោមសកម្មភាពចំនួន៤ ត្រូវបានដាក់ឱ្យអនុវត្តដូច ខាងក្រោម៖

១.ផែនការយុទ្ធសាស្ត្រជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ២០២៥-២០២៨
២.ការកែលម្អការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន
៣.ការកែទម្រង់ការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេស/មន្ត្រីជំនាញតាមកិច្ចសន្យា
៤.ការអភិវឌ្ឍវេទិកាព័ត៌មានវិទ្យាជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ។

### ៣.២.វិធានការគន្លឹះទី២៖ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព

ការបំពេញការងាររបស់មន្ត្រីក្នុងរដ្ឋបាលសាធារណៈ នឹងត្រូវលើកកម្ពស់ឱ្យមានភាពប្រសើរឡើង ទាំងប្រសិទ្ធភាព និងផលិតភាពការងារ ព្រមទាំងការទទួលខុសត្រូវ ដោយផ្តើមចេញពីការពិនិត្យ និងវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃការបំពេញការងាររបស់មន្ត្រី រួមទាំងការគិតគូរអំពីវិធានការដោះស្រាយ ដើម្បីពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន។

ដើម្បីសម្រេចបាននូវវិធានការគន្លឹះទី២ ចង្កោមសកម្មភាពចំនួន៤ ត្រូវបានដាក់ឱ្យអនុវត្តដូច ខាងក្រោម៖

១.ផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពការងាររបស់មន្ត្រី និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន (ថ្នាក់ជាតិ) ២០២៤-២០២៨

២.ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន

៣.ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ

៤.ការអភិវឌ្ឍសមត្ថភាព និងភាពជាអ្នកដឹកនាំ។

### ៣.៣.វិធានការគន្លឹះទី៣៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព

វិធានការនៃការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ឬ របបឧបត្ថម្ភបន្ថែម ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន ត្រូវបានពិនិត្យឡើងវិញ និងធ្វើការកែលម្អ រួមជាមួយនឹងវិធានការថ្មីៗបន្ថែមទៀត ព្រមទាំងការផ្តល់ធនធានគាំទ្រ ការរៀបចំក្របខណ្ឌគតិយុត្ត និងយន្តការស្ថាប័ន ដើម្បីជានាប្រព័ន្ធនៃការលើកទឹកចិត្តបន្ថែមឈរលើគោលការណ៍គាំទ្រសមិទ្ធកម្ម សង្គតិភាព សមធម៌ និងចីរភាពនៃថវិកាទ្រទ្រង់បាន។

ដើម្បីសម្រេចបាននូវវិធានការគន្លឹះទី៣ ចង្កោមសកម្មភាពចំនួន២ ត្រូវបានដាក់ឱ្យអនុវត្តដូចខាងក្រោម៖

១.ផែនការយុទ្ធសាស្ត្រនៃការកសាងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ២០២៤-២០២៨

២.ការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។

## ៤.យន្តការស្ថាប័នទទួលបន្ទុកអនុវត្តសកម្មភាព

### ៤.១.យន្តការអនុវត្តក្នុងក្របខណ្ឌលេខាធិការដ្ឋាននៃ គ.ជ.រ.

គំនូសបំព្រួញទី១. យន្តការក្របខណ្ឌលេខាធិការដ្ឋាននៃ គ.វ.រ.



**តារាងទី១. តួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននៃ គ.វ.រ.**

| សមត្ថកិច្ច | ភារកិច្ច និងការទទួលខុសត្រូវ |
|---|---|
| លេខាធិការដ្ឋាននៃ គ.វ.រ. | - ដឹកនាំ និងសម្របសម្រួលក្នុងការរៀបចំ និងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាព និងវិធានការចាំបាច់នានា<br>- កំណត់នូវក្របខណ្ឌសមិទ្ធកម្មដែលរួមមានសូចនាករ គោលដៅ និងវិធីសាស្ត្រវាស់វែងក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្ដោតលើ៖<br>▪ ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី<br>▪ ការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ<br>▪ ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ<br>- ដឹកនាំសម្របសម្រួលអង្គភាពចំណុះក្រសួង ស្ថាប័ន ដើម្បីអនុវត្តយុទ្ធសាស្ត្រ ផែនការសកម្មភាព និងវិធានការនានាក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ<br>- រៀបចំយន្តការផ្ទៃក្នុងក្រសួង និងកំណត់បែបបទ និងនីតិវិធីដើម្បីធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ<br>- សម្របសម្រួល ផ្ដល់ការតម្រង់ទិស ផ្ដល់ការគាំទ្រ និងដោះស្រាយបញ្ហាប្រឈមនានា ដែលកើតមានក្នុងក្របខណ្ឌនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ<br>- សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញ និងគាំទ្រដល់ការរៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រ វិធានការ និងផែនការសកម្មភាពក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ<br>- សហការ និងសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ក្នុងការរៀបចំ និងអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ។ |
| អនុគណៈកម្មាធិការប្រតិបត្តិនៃ គ.វ.រ. | - ដឹកនាំ សម្របសម្រួល និងតម្រង់ទិសការងារបច្ចេកទេសក្នុងការរៀបចំនិងអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា រួមមាន ការរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព វិធានការចាំបាច់នានា និងការកំណត់នូវក្របខណ្ឌសមិទ្ធកម្មដែលរួមមានសូចនាករ គោលដៅ និងវិធីសាស្ត្រវាស់វែង ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ដោយផ្ដោតសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន តាមរយៈការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី |

| | |
|---|---|
| | ការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ និងការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ<br>- លើកសំណើអំពីយុទ្ធសាស្ត្រ ផែនការសកម្មភាព វិធានការចាំបាច់នានា និងក្របខណ្ឌសមិទ្ធកម្មសម្រាប់ការដាក់ឱ្យអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ជូន គ.វ.រ. ដើម្បីពិនិត្យ និងសម្រេច តាមរយៈលេខាធិការដ្ឋាននៃ គ.វ.រ.<br>- សម្របសម្រួលនិងផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ដើម្បីបំពេញតួនាទី និងភារកិច្ចឱ្យមានប្រសិទ្ធភាពខ្ពស់<br>- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការរៀបចំ និងការដាក់ឱ្យអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា<br>- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូនលេខាធិការដ្ឋាននៃ គ.វ.រ.។ |
| ក្រុមការងារបច្ចេកទេសកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី | - ពិនិត្យ និងសិក្សាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន ឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការជ្រើសរើស និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្នុងរដ្ឋបាលសាធារណៈ<br>- រៀបចំ និងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ កំណត់សូចនាករសមិទ្ធកម្ម ក្របខណ្ឌពេលវេលាអនុវត្ត ក្របខណ្ឌនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រ និងមធ្យោបាយផ្សេងទៀត ដើម្បីដាក់ឱ្យអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ឈរលើគោលការណ៍គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព។ |
| ក្រុមការងារបច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ | - ពិនិត្យ និងសិក្សាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន ឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការរៀបចំ រចនាសម្ព័ន្ធស្ថាប័ន មុខងារ របៀបរបបការងារ និងដំណើរការរដ្ឋបាល ការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្នុងរដ្ឋបាលសាធារណៈ<br>- រៀបចំ និងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ កំណត់សូចនាករសមិទ្ធកម្ម ក្របខណ្ឌពេលវេលាអនុវត្ត ក្របខណ្ឌនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រ និងមធ្យោបាយផ្សេងទៀត ដើម្បីដាក់ឱ្យអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់ |

| | |
|---|---|
| | គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ |
| ក្រុមការងារបច្ចេកទេសរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម | - ពិនិត្យ និងសិក្សាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន ឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការរៀបចំប្រព័ន្ធលើកទឹកចិត្តក្នុងរដ្ឋបាលសាធារណៈ<br>- រៀបចំ និងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ កំណត់សូចនាករសមិទ្ធកម្ម ក្របខណ្ឌពេលវេលាអនុវត្ត ក្របខណ្ឌនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រ និងមធ្យោបាយផ្សេងទៀត ដើម្បីដាក់ឱ្យអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការកែលម្អប្រព័ន្ធលើកទឹកចិត្ត ផ្អែកលើសមិទ្ធកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ ឈរលើគោលការណ៍សង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។ |
| អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | - ជាអង្គភាពសម្របសម្រួលរួមក្នុងការជួយក្រសួងមុខងារសាធារណៈ ដើម្បីបំពេញតួនាទី និងភារកិច្ចក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ |

### ៤.២. យន្តការអនុវត្តក្នុងក្របខណ្ឌនៃអន្តរ-លេខាធិការដ្ឋាននៃការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

ដើម្បីអនុវត្តផែនការសកម្មភាពគាំទ្រដល់ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា យន្តការក្នុងក្របខណ្ឌនៃអន្តរ-លេខាធិការដ្ឋាន នឹងត្រូវរៀបចំ និងអនុវត្តដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡាគ្នា និងសុខដុមនីយកម្មនៃទំនាក់ទំនងការងារកែទម្រង់នៃលេខាធិការដ្ឋានទាំងបី រួមមាន៖ គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (**គ.រ.រ.**) គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (**គ.រ.ស.**) និងគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (**គ.រ.អ.**)។

## ៥. ធនធានគាំទ្រការអនុវត្តសកម្មភាព

ប្រភពធនធាន ដែលគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការសកម្មភាព ២០២៤-២០២៨ បានមកពីថវិកាជាតិ និងប្រភពថវិកាស្របច្បាប់ផ្សេងទៀត។

រាជរដ្ឋាភិបាល នឹងផ្តល់ការលើកទឹកចិត្តទាំងផ្នែកហិរញ្ញវត្ថុ និង/ឬមិនមែនហិរញ្ញវត្ថុដល់មន្ត្រីក្រុមការងារ ដែលបំពេញការងារក្នុងក្របខណ្ឌនៃការផ្តួចផ្តើម ដឹកនាំ គ្រប់គ្រង សម្របសម្រួល គាំទ្រ និងជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។ សម្រាប់ថវិកានៃការលើកទឹកចិត្តគាំទ្រនេះ ត្រូវធ្វើការពិភាក្សា និងពិគ្រោះយោបល់ជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៦.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

នៅក្នុងការធានាបាននូវវឌ្ឍនភាពការងារ និងប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា រួមមាន ចង្កោមសកម្មភាព និងសូចនាករសមិទ្ធកម្មដែលបានកំណត់ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺមានភាពចាំបាច់ ដែលត្រូវរៀបចំឡើង និងអនុវត្តជាប្រចាំដោយលេខាធិការដ្ឋាននៃ គ.វ.រ.។

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាព សមិទ្ធផល និងបញ្ហាប្រឈមក្នុងការអនុវត្តវិធានការគន្លឹះនេះ លេខាធិការដ្ឋាននៃ គ.វ.រ. ត្រូវបង្កើតប្រព័ន្ធ ឬ យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃជាក់លាក់មួយសម្រាប់វាស់វែងទៅលើប្រសិទ្ធភាពនៃការអនុវត្ត សមិទ្ធកម្ម សមិទ្ធផល និងផលវិបាកនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ។

ទន្ទឹមនេះ ការតាមដានត្រួតពិនិត្យ អាចត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពការងារ។ ការវាយតម្លៃ ត្រូវរៀបចំអនុវត្តដោយផ្តោតលើៈ ទី១.ការវាយតម្លៃលើការអនុវត្តផែនការសកម្មភាពអាទិភាពដែលបានកំណត់ និងទី២.ការប្រៀបធៀបលទ្ធផលទៅនឹងសូចនាករដែលបានកំណត់។ លទ្ធផលនៃការវាយតម្លៃ និងការពិនិត្យអំពីការវាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត នឹងក្លាយជាមូលដ្ឋាន និងអនុសាសន៍ដើម្បីធ្វើការកែតម្រូវ និងតម្រង់ទិសសម្រាប់ការអនុវត្ត។ ការវាយតម្លៃអាចធ្វើឡើងជារៀងរាល់១ (មួយ) ឆ្នាំម្តង។

## ៧. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នៅតែបន្តពង្រឹង និងលើកកម្ពស់ការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈការដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលក្នុងនោះក្រសួងមុខងារសាធារណៈ បានដើរតួនាទីយ៉ាងសកម្មក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ ផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តសម្រាប់រយៈពេលចាប់ពីឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៨។

ផែនការសកម្មភាព ២០២៤-២០២៨ ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានរៀបចំឡើង ដោយផ្អែកលើវិធានការគន្លឹះទាំងបីក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលដាក់ចេញដោយរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា រួមមាន ទី១.ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ ប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន ទី២.ការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពការងារប្រកបដោយវិន័យ សីលធម៌ និងវិជ្ជាជីវៈ និងទី៣.ការរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព។

គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា គឺជាយន្តការដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការអនុវត្តផ្ទាល់

ក៏ដូចជាផ្តល់កិច្ចសហការជាមួយគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.អ.) គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.ស.) និងក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូពាក់ព័ន្ធផ្សេងទៀតក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ។

ទន្ទឹមនេះ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ គឺជាកត្តាចម្បងក្នុងការជំរុញបន្ថែមទៀតដល់ដំណើរការនៃការអនុវត្ត និងវឌ្ឍនភាពនៃវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសជាកញ្ចក់ឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាព ថាមភាព និងវិសាលភាពរបស់ផែនការសកម្មភាព ដែលបានរៀបចំឡើង។

ជារួម ផែនការសកម្មភាពដែលបានរៀបចំនេះ នឹងក្លាយជាមូលដ្ឋានដ៏មានសារៈសំខាន់ក្នុងការជំរុញនិងពង្រឹងរដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ក្នុងគោលដៅបម្រើឧត្តមប្រយោជន៍ជាតិ និងឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាជន។

**ឧបសម្ព័ន្ធ**

# ផែនការសកម្មភាពអនុវត្តវិធានការគន្លឹះ
# ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

| ល.រ | | វិធានការគន្លឹះ និងចង្កោមសកម្មភាព | | |
|---|---|---|---|---|
| | | **ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម** | | |
| | | **២០២៤** | **២០២៥ - ២០២៦** | **២០២៧ - ២០២៨** |
| **វិធានការគន្លឹះទី១៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព** | | | | |
| **១.១** | **ចង្កោមសកម្មភាពទី១៖ ផែនការយុទ្ធសាស្ត្រជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ: ២០២៥-២០២៨** | | | |
| | ១.១.១ | ផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ការជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ: ២០២៥-២០២៨ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ការជ្រើសរើសមន្ត្រី និងកម្មវិធីពង្រាយមន្ត្រីសម្រាប់ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវបានអនុវត្តផ្អែកលើផែនការ | ការជ្រើសរើសមន្ត្រី និងកម្មវិធីពង្រាយមន្ត្រីសម្រាប់ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវបានអនុវត្តផ្អែកលើផែនការ |
| | ១.១.២ | ផែនការគ្រប់គ្រង និងជ្រើសរើសមន្ត្រីសម្រាប់បម្រើការងារនៅតាមមត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ២០២៥-២០២៨ ត្រូវបានរៀបចំ | ការជ្រើសរើសមន្ត្រី និងកម្មវិធីពង្រាយមន្ត្រីសម្រាប់បម្រើការងារនៅតាមសាលាមត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ត្រូវបានអនុវត្តផ្អែកលើផែនការ | ការជ្រើសរើសមន្ត្រី និងកម្មវិធីពង្រាយមន្ត្រីសម្រាប់បម្រើការងារនៅតាមសាលាមត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ត្រូវបានអនុវត្តផ្អែកលើផែនការ |
| | ១.១.៣ | ផែនការគ្រប់គ្រង និងជ្រើសរើសមន្ត្រីសម្រាប់បម្រើការងារនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ ២០២៤-២០២៨ ត្រូវបានរៀបចំ | ការជ្រើសរើសមន្ត្រី និងកម្មវិធីពង្រាយមន្ត្រីសម្រាប់បម្រើការងារនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ ត្រូវបានអនុវត្តផ្អែកលើផែនការ | ការជ្រើសរើសមន្ត្រី និងកម្មវិធីពង្រាយមន្ត្រីសម្រាប់បម្រើការងារនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ ត្រូវបានអនុវត្តផ្អែកលើផែនការ |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| ១.២ | ចង្កោមសកម្មភាពទី២៖ ការកែលម្អការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន | | | |
| | ១.២.១ | ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ផ្អែកលើគោលការណ៍ថ្មី សម្រាប់ក្រសួង ស្ថាប័ន ដែលទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាល ក្នុងឆ្នាំ២០២៣ ត្រូវបានរៀបចំ៖<br>- មន្ត្រីកសិកម្មឃុំ-លើកទី១ (២៥០នាក់)<br>- មន្ត្រីអប់រំកាយ និងកីឡារបស់ក្រសួងអប់រំ យុវជន និងកីឡា (១០០នាក់)<br>- មន្ត្រីរបស់អង្គភាពប្រឆាំងអំពើពុករលួយ (ចំនួន ៣៣ នាក់)<br>- មន្ត្រីរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (ចំនួន ៩៩ នាក់)<br>- មន្ត្រីជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ចំនួន ៥២ នាក់)<br>- គ្រូមត្តេយ្យសិក្សា គ្រូបឋមសិក្សា និងគ្រូអនុវិទ្យាល័យ (សរុបចំនួន ១៩៨៨ នាក់)<br>- មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ (ចំនួន ៦ នាក់)<br>- មន្ត្រីកសិកម្មឃុំ-លើកទី២ (ចំនួន ៨០០ នាក់)។ | មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ត្រូវបានប្រឡងជ្រើសរើស ផ្អែកលើផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ការជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ២០២៥-២០២៨ និងផែនការក្របខណ្ឌប្រចាំឆ្នាំ | មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ត្រូវបានប្រឡងជ្រើសរើស ផ្អែកលើផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ការជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ២០២៥-២០២៨ និងផែនការក្របខណ្ឌប្រចាំឆ្នាំ |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| | ១.២.២ | អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួងស្ថាប័ន ត្រូវបានអនុវត្តផ្អែកលើនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល | ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួងស្ថាប័ន ត្រូវបានអនុវត្តផ្អែកលើនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល |
| ១.៣ | **ចង្កោមសកម្មភាពទី៣៖ ការកែទម្រង់ការជ្រើសរើស និងការប្រើប្រាស់មន្ត្រីបច្ចេកទេស/មន្ត្រីជំនាញ (តាមកិច្ចសន្យា)** | | | |
| | ១.៣.១ | - ក្របខណ្ឌគតិយុត្តនៃការជ្រើសរើស និងគ្រប់គ្រងមន្ត្រីបច្ចេកទេសសុខាភិបាល (ផ្អែកលើកិច្ចសន្យា) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- មន្ត្រីបច្ចេកទេសសុខាភិបាល ត្រូវបានជ្រើសរើសជាដំណាក់កាលៗផ្អែកលើលទ្ធផលនៃបច្ចុប្បន្នភាពទិន្នន័យមន្ត្រី និងកម្រិតអាទិភាពនៃតម្រូវការនៅតាមអង្គភាពសុខាភិបាលមូលដ្ឋាន | មន្ត្រីបច្ចេកទេសសុខាភិបាល ត្រូវបានជ្រើសរើសផ្អែកលើផែនការគ្រប់គ្រង និងជ្រើសរើសមន្ត្រីសម្រាប់បម្រើការងារនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ (២០២៤-២០២៨) | មន្ត្រីបច្ចេកទេសសុខាភិបាល ត្រូវបានជ្រើសរើសផ្អែកលើផែនការគ្រប់គ្រង និងជ្រើសរើសមន្ត្រីសម្រាប់បម្រើការងារនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ (២០២៤-២០២៨) |
| | ១.៣.២ | ក្របខណ្ឌគតិយុត្តនៃការជ្រើសរើស និងគ្រប់គ្រងមន្ត្រីជំនាញអប់រំ (ផ្អែកលើកិច្ចសន្យា) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | មន្ត្រីបច្ចេកទេសសុខាភិបាល ត្រូវបានជ្រើសរើសផ្អែកលើផែនការគ្រប់គ្រង និងជ្រើសរើសមន្ត្រីសម្រាប់បម្រើការងារនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ (២០២៤-២០២៨) | មន្ត្រីបច្ចេកទេសសុខាភិបាល ត្រូវបានជ្រើសរើសផ្អែកលើផែនការគ្រប់គ្រង និងជ្រើសរើសមន្ត្រីសម្រាប់បម្រើការងារនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២ (២០២៤-២០២៨) |
| | ១.៣.៣ | ក្របខណ្ឌគតិយុត្តនៃការជ្រើសរើស និងគ្រប់គ្រងមន្ត្រីបច្ចេកទេស/ជំនាញ (ផ្អែកលើកិច្ចសន្យា) របស់ | មន្ត្រីបច្ចេកទេស/ជំនាញរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានជ្រើសរើសផ្អែកលើផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ការជ្រើសរើស | មន្ត្រីបច្ចេកទេស/ជំនាញរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានជ្រើសរើសផ្អែកលើផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ការជ្រើសរើស |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| | | ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | មន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ២០២៥-២០២៨ និងផែនការក្របខណ្ឌប្រចាំឆ្នាំ | មន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ២០២៥-២០២៨ និងផែនការក្របខណ្ឌប្រចាំឆ្នាំ |
| **១.៤** | **ចង្កោមសកម្មភាពទី៤៖ ការអភិវឌ្ឍថ្នាលព័ត៌មានវិទ្យាជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ** | | | |
| | ១.៤.១ | ថ្នាលព័ត៌មានវិទ្យាជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ត្រូវបានរៀបចំ | ថ្នាលព័ត៌មានវិទ្យាជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ត្រូវបានដាក់ឱ្យដំណើរការសម្រាប់ដំណើរការជ្រើសរើសមន្ត្រីរាជការ និងមន្ត្រីបច្ចេកទេស/មន្ត្រីជំនាញ | ថ្នាលព័ត៌មានវិទ្យាជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ត្រូវបានដាក់ឱ្យដំណើរការសម្រាប់ដំណើរការជ្រើសរើសមន្ត្រីរាជការ និងមន្ត្រីបច្ចេកទេស/មន្ត្រីជំនាញ |
| **វិធានការគន្លឹះទី២៖ ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | |
| **២.១** | **ចង្កោមសកម្មភាពទី១៖ ផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពការងាររបស់មន្ត្រី និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន (ថ្នាក់ជាតិ) ២០២៤-២០២៨** | | | |
| | ២.១.១ | ផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពការងាររបស់មន្ត្រី និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន (ថ្នាក់ជាតិ) ២០២៤-២០២៨ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តដោយផ្អែកលើ៖<br>- ប្រភេទ និងកម្រិតអង្គភាព<br>- ប្រភេទនៃសកម្មភាព (ការងារអាទិភាពនិងប្រចាំថ្ងៃ)<br>- ប្រភេទនិងកម្រិតនៃវិធានការ | ផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពការងាររបស់មន្ត្រី និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន (ថ្នាក់ជាតិ) ២០២៤-២០២៨ ត្រូវបានអនុវត្ត | ផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពការងាររបស់មន្ត្រី និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន (ថ្នាក់ជាតិ) ២០២៤-២០២៨ ត្រូវបានអនុវត្ត |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| ២.២ | **ចង្កោមសកម្មភាពទី២៖ ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន** | | | |
| | ២.២.១ | សេចក្តីណែនាំស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីកំណត់បានច្បាស់លាស់៖<br>- មុខងារ និងរចនាសម្ព័ន្ធ<br>- តម្រូវការធនធានមនុស្ស<br>- តម្រូវការអភិវឌ្ឍសមត្ថភាពមន្ត្រី<br>- កម្មវិធីពង្រាយមន្ត្រីរាជការក្នុង/ក្រៅក្រសួង ស្ថាប័ន | សេចក្តីណែនាំស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត | សេចក្តីណែនាំស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត |
| | ២.២.២ | ផែនការសកម្មភាពសម្រាប់ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់អង្គភាពនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ ២០២៤-២០២៨ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់មុខងារស្នូល៖<br>- ធនធានមនុស្ស<br>- ថវិកា<br>- គោលនយោបាយ<br>- ផែនការ<br>- បរិវត្តកម្មឌីជីថល | ផែនការសកម្មភាពសម្រាប់ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់អង្គភាពនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ ២០២៤-២០២៨ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់មុខងារស្នូល៖<br>- នីតិកម្ម<br>- សវនកម្ម<br>- អធិការកិច្ច<br>- ទំនាក់ទំនងសាធារណៈ<br>- ទំនាក់ទំនងអន្តរជាតិ | ផែនការសកម្មភាពសម្រាប់ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់អង្គភាពនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ ២០២៤-២០២៨ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់មុខងារជំនាញៗ |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| | ២.២.៣ | របនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីនៅតាមសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវបានធ្វើបច្ចុប្បន្នភាពនិងចងក្រងពេញលេញ តាមប្រព័ន្ធព័ត៌មានវិទ្យា | របនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ ត្រូវបានធ្វើបច្ចុប្បន្នភាពនិងចងក្រងពេញលេញ តាមប្រព័ន្ធព័ត៌មានវិទ្យា | របនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីនៅតាមសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ តាមប្រព័ន្ធព័ត៌មានវិទ្យា និងផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ |
| | ២.២.៤ | របនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក កម្រិត១ និងកម្រិត២ ត្រូវបានធ្វើបច្ចុប្បន្នភាពនិងចងក្រងពេញលេញ តាមប្រព័ន្ធព័ត៌មានវិទ្យា | របនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីនៅតាមមន្ទីរពេទ្យបង្អែកកម្រិត៣ ត្រូវបានធ្វើបច្ចុប្បន្នភាព និងចងក្រងពេញលេញ តាមប្រព័ន្ធព័ត៌មានវិទ្យា | របនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក កម្រិត១ កម្រិត២ និងកម្រិត៣ ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ តាមប្រព័ន្ធព័ត៌មានវិទ្យានិងផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ |
| | ២.២.៥ | របនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីនៅតាមអង្គភាពរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវបានធ្វើបច្ចុប្បន្នភាព | របនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីនៅតាមអង្គភាពរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំនិងផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ | របនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីនៅតាមអង្គភាពរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំនិងផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ |
| ២.៣ | ចង្កោមសកម្មភាពទី៣៖ ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ | | | |
| | ២.៣.១ | កម្មវិធីពង្រឹងការគ្រប់គ្រងវត្តមាន និងការបំពេញការងាររបស់មន្ត្រីនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំនិងអនុវត្ត តាមរយៈ៖ | - ការគ្រប់គ្រងវត្តមានមន្ត្រីនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង<br>- ផែនការសកម្មភាពរបស់អង្គភាពកម្រិតនាយកដ្ឋាន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | - ការគ្រប់គ្រងវត្តមានមន្ត្រីនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង<br>- ផែនការសកម្មភាពរបស់អង្គភាពកម្រិតការិយាល័យ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| | | - ការគ្រប់គ្រងវត្តមានមន្ត្រីនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ការដាក់ឱ្យអនុវត្តផែនការសកម្មភាពរបស់អង្គភាពកម្រិតអគ្គនាយកដ្ឋាននិងអង្គភាពប្រហាក់ប្រហែល<br>- ការពិពណ៌នាការងារមន្ត្រីកម្រិតដឹកនាំអង្គភាព | - ការពិពណ៌នាការងារមន្ត្រីនៅក្នុងនាយកដ្ឋាន ផ្អែកលើផែនការសកម្មភាព ត្រូវបានរៀបចំពេញលេញ<br>- ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពកម្រិតអគ្គនាយកដ្ឋាន ផ្សារភ្ជាប់នឹងថវិកាសមិទ្ធកម្ម ត្រូវបានអនុវត្ត | - ការពិពណ៌នាការងារមន្ត្រីនៅក្នុងការិយាល័យ ផ្អែកលើផែនការសកម្មភាព ត្រូវបានរៀបចំពេញលេញ<br>- ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពកម្រិតនាយកដ្ឋាន ផ្សារភ្ជាប់នឹងថវិកាសមិទ្ធកម្ម ត្រូវបានអនុវត្ត |
| | ២.៣.២ | និយាមនីតិវិធីប្រតិបត្តិរបស់អង្គភាពក្នុងរដ្ឋបាលសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់៖<br>- អង្គភាពផ្តល់សេវាសាធារណៈ<br>- អង្គភាពកម្រិតអគ្គនាយកដ្ឋាន | និយាមនីតិវិធីប្រតិបត្តិរបស់អង្គភាពក្នុងរដ្ឋបាលសាធារណៈ ត្រូវបានពិនិត្យវាយតម្លៃ និងធ្វើបច្ចុប្បន្នភាព៖<br>- អង្គភាពផ្តល់សេវាសាធារណៈ<br>- អង្គភាពកម្រិតអគ្គនាយកដ្ឋាន | និយាមនីតិវិធីប្រតិបត្តិរបស់អង្គភាពក្នុងរដ្ឋបាលសាធារណៈ ត្រូវបានពិនិត្យវាយតម្លៃ និងកែលម្អ៖<br>- អង្គភាពផ្តល់សេវាសាធារណៈ<br>- អង្គភាពកម្រិតអគ្គនាយកដ្ឋាន |
| | ២.៣.៣ | កម្មវិធីលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈក្នុងរដ្ឋបាលសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តតាមរយៈ៖<br>- ការដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិក្នុងរដ្ឋបាលសាធារណៈ<br>- ការរៀបចំកម្មវិធីបណ្តុះបណ្តាលអំពីក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិ សម្រាប់ថ្នាក់ដឹកនាំអង្គភាព | ការដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលអំពីក្រមសីលធម៌ និងក្រមប្រតិបត្តិសម្រាប់ថ្នាក់ដឹកនាំអង្គភាពឱ្យបានយ៉ាងហោច ៥០%៖<br>- អគ្គនាយកដ្ឋាន និងនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល<br>- នាយក និងនាយករងគ្រឹះស្ថានសិក្សានៅមូលដ្ឋាន<br>- ប្រធាន/អនុប្រធានអង្គភាពសុខាភិបាលនៅមូលដ្ឋាន | ការដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលអំពីក្រមសីលធម៌ និងក្រមប្រតិបត្តិសម្រាប់ថ្នាក់ដឹកនាំអង្គភាពឱ្យបានយ៉ាងហោច ៥០%៖<br>- អគ្គនាយកដ្ឋាន និងនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល<br>- នាយក និងនាយករងគ្រឹះស្ថានសិក្សានៅមូលដ្ឋាន<br>- ប្រធាន/អនុប្រធានអង្គភាពសុខាភិបាលនៅមូលដ្ឋាន |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| | ២.៣.៤ | អភិបាលកិច្ច និងភាពជាអ្នកដឹកនាំអង្គភាពនៃគ្រឹះស្ថានសិក្សានៅមូលដ្ឋាន (មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ) ត្រូវបានពង្រឹងតាមរយៈ៖<br>- ការគ្រប់គ្រងវត្តមាន និងការបំពេញការងាររបស់មន្ត្រីនៃគ្រឹះស្ថានសិក្សា<br>- សេចក្តីណែនាំអន្តរក្រសួងស្តីពីការតែងតាំងនាយកនាយិកាគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ត្រូវបានរៀបចំ និងដាក់អនុវត្ត ដើម្បីពង្រឹងការតែងតាំងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ឱ្យបានប្រសើរ និងកាន់តែមានប្រសិទ្ធភាព<br>- សេចក្តីណែនាំអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្ទេរ និងផ្លាស់ប្តូរកន្លែងការងាររបស់មន្ត្រីអប់រំនៃគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ត្រូវបានរៀបចំ និងដាក់អនុវត្ត ដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីឱ្យបានប្រសើរ និងកាន់តែមានប្រសិទ្ធភាព | - កម្មវិធីពង្រឹងការគ្រប់គ្រងវត្តមាននិងការបំពេញការងាររបស់មន្ត្រីនៃគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ត្រូវបានអនុវត្តបន្ត និងវាយតម្លៃ<br>- ផែនការសកម្មភាពរបស់គ្រឹះស្ថានសិក្សានៅមូលដ្ឋាន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- និយាមនីតិវិធីប្រតិបត្តិរបស់គ្រឹះស្ថានសិក្សាសាធារណៈ (មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ផ្សារភ្ជាប់នឹងថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរវាងគ្រូបង្រៀនជាមួយនាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវបានអនុវត្ត | - កម្មវិធីពង្រឹងការគ្រប់គ្រងវត្តមាននិងការបំពេញការងាររបស់មន្ត្រីនៃគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ត្រូវបានអនុវត្តបន្តនិងវាយតម្លៃ<br>- ផែនការសកម្មភាពរបស់គ្រឹះស្ថានសិក្សានៅមូលដ្ឋាន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មគ្រឹះស្ថានសិក្សានៅមូលដ្ឋាន ផ្សារភ្ជាប់នឹងថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- កិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរវាងគ្រូបង្រៀនជាមួយនាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវបានអនុវត្ត |
| | ២.៣.៥ | អភិបាលកិច្ចនិងភាពជាអ្នកដឹកនាំអង្គភាពនៃអង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ដើម្បីធានាបានការបម្រើសេវាសុខាភិបាល ២៤ម៉ោង/២៤ម៉ោង ត្រូវបានពង្រឹងតាមរយៈ៖ | - កម្មវិធីពង្រឹងការគ្រប់គ្រងវត្តមាន និងការបំពេញការងាររបស់មន្ត្រីនៅតាមអង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានបន្តអនុវត្ត និងវាយតម្លៃ | - កម្មវិធីពង្រឹងការគ្រប់គ្រងវត្តមាន និងការបំពេញការងាររបស់មន្ត្រីនៅតាមអង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានបន្តអនុវត្ត និងវាយតម្លៃ |

| ល.រ | | វិធានការគន្លឹះ និងចង្កោមសកម្មភាព | | |
|---|---|---|---|---|
| | | **ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម** | | |
| | | **២០២៤** | **២០២៥ - ២០២៦** | **២០២៧ - ២០២៨** |
| | | - កម្មវិធីពង្រឹងការគ្រប់គ្រងវត្តមាន និងការបំពេញការងាររបស់មន្ត្រីនៅតាមអង្គភាពសុខាភិបាលមូលដ្ឋាន<br>- សេចក្តីណែនាំអន្តរក្រសួងស្តីពីការតែងតាំងប្រធានអង្គភាពសុខាភិបាលមូលដ្ឋាន ត្រូវបានរៀបចំនិងដាក់អនុវត្ត ដើម្បីពង្រឹងការដឹកនាំនិងគ្រប់គ្រងឱ្យបានប្រសើរ និងកាន់តែមានប្រសិទ្ធភាព<br>- សេចក្តីណែនាំអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្ទេរ និងផ្លាស់ប្តូរកន្លែងការងាររបស់មន្ត្រីសុខាភិបាលនៃអង្គភាពសុខាភិបាលមូលដ្ឋាន ត្រូវបានរៀបចំ និងដាក់អនុវត្ត ដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីឱ្យបានប្រសើរ និងកាន់តែមានប្រសិទ្ធភាព | - ផែនការសកម្មភាពរបស់អង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- និយាមនីតិវិធីប្រតិបត្តិរបស់អង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានរៀបចំឱ្យមានសង្គតិភាពជាមួយសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្គ្រប់សម្រាប់មន្ទីរពេទ្យបង្អែក (CPA) និងសេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមាសម្រាប់មណ្ឌលសុខភាព (MPA) និងដាក់ឱ្យអនុវត្ត<br>- ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានរៀបចំនិងអនុវត្តតាមទម្រង់គំរូស្តង់ដារ និងយោងតាមស្ថានភាពអង្គភាពសាមី | - ផែនការសកម្មភាពរបស់អង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានរៀបចំនិងអនុវត្តតាមទម្រង់គំរូស្តង់ដារ និងយោងតាមស្ថានភាពអង្គភាពសាមី |
| ២.៤ | **ចង្កោមសកម្មភាពទី៤៖ ការអភិវឌ្ឍសមត្ថភាព និងភាពជាអ្នកដឹកនាំ** | | | |
| | ២.៤.១ | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំនៅតាមអង្គភាពកម្រិតអគ្គនាយកដ្ឋាន និងប្រហាក់ប្រហែល ត្រូវបានរៀបចំ | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំនៅតាមអង្គភាព រួមទាំងវេទិកាបណ្តាញអ្នកដឹកនាំអង្គភាព ត្រូវបានដាក់ឱ្យអនុវត្ត សម្រាប់មន្ត្រីក្នុងតំណែងកម្រិតអគ្គនាយក | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំនៅតាមអង្គភាព រួមទាំងវេទិកាបណ្តាញអ្នកដឹកនាំអង្គភាព ត្រូវបានដាក់ឱ្យអនុវត្ត សម្រាប់មន្ត្រីក្នុងតំណែងកម្រិតអគ្គ |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | |
|---|---|---|---|
| ល.រ | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| | | នាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | នាយក នាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២.៤.២ | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ (មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ) ត្រូវបានរៀបចំ | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំដល់នាយកសាលាកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា រួមជាមួយវេទិកាបណ្តាញអ្នកដឹកនាំអង្គភាព ត្រូវបានដាក់ឱ្យអនុវត្ត | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំដល់នាយកសាលាកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ រួមជាមួយវេទិកាបណ្តាញអ្នកដឹកនាំអង្គភាព ត្រូវបានដាក់ឱ្យអនុវត្ត |
| ២.៤.៣ | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំនៅតាមអង្គភាពសុខាភិបាលមូលដ្ឋាន (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) ត្រូវបានរៀបចំ | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំរបស់អង្គភាពសុខាភិបាលមូលដ្ឋានត្រូវបានដាក់ឱ្យអនុវត្តសម្រាប់៥០% នៃ៖<br>- ១ ៣០៥ មណ្ឌលសុខភាព<br>- ៦១ មន្ទីរពេទ្យបង្អែកកម្រិត១<br>- ៣៩ មន្ទីរពេទ្យបង្អែកកម្រិត២ | កម្មវិធីពង្រឹងភាពជាអ្នកដឹកនាំរបស់អង្គភាពសុខាភិបាលមូលដ្ឋានត្រូវបានដាក់ឱ្យអនុវត្តសម្រាប់៥០% នៃ៖<br>- ១ ៣០៥ មណ្ឌលសុខភាព<br>- ៦១ មន្ទីរពេទ្យបង្អែកកម្រិត១<br>- ៣៩ មន្ទីរពេទ្យបង្អែកកម្រិត២ |
| ២.៤.៤ | កម្មវិធីបណ្តុះបណ្តាលត្រូវបានអនុវត្តសម្រាប់មន្ត្រីក្នុងមុខងារគន្លឹះរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធផ្ទាល់ក្នុងការអនុវត្តវិធានការគន្លឹះកែទម្រង់ លើផ្នែក៖<br>- ធនធានមនុស្ស<br>- ថវិកា<br>- គោលនយោបាយ<br>- ផែនការ | កម្មវិធីបណ្តុះបណ្តាលត្រូវបានអនុវត្ត | ការពិនិត្យនិងវាយតម្លៃអំពីផលនៃការបណ្តុះបណ្តាល |

| ល.រ | | វិធានការគន្លឹះ និងចង្កោមសកម្មភាព<br>ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម<br>២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
|---|---|---|---|---|
| | | - ព័ត៌មានវិទ្យា<br>- ត្រួតពិនិត្យ និងវាយតម្លៃ | | |
| | ២.៤.៥ | កម្មវិធី និងផែនការបណ្តុះបណ្តាលត្រូវបានរៀបចំសម្រាប់មន្ត្រីដែលមានតួនាទី និងភារកិច្ចក្នុងការចូលរួមអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ និងសុខាភិបាលៈ<br>- គណៈអភិបាលនិងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ<br>- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត<br>- មន្ទីរសុខាភិបាលរាជធានី ខេត្ត<br>- ការិយាល័យអប់រំ<br>- ការិយាល័យស្រុកប្រតិបត្តិ (សុខាភិបាល)<br>- ក្រុមប្រឹក្សាឃុំ សង្កាត់ | កម្មវិធីបណ្តុះបណ្តាលត្រូវបានអនុវត្ត | ការពិនិត្យនិងវាយតម្លៃអំពីផលនៃការបណ្តុះបណ្តាល |
| **វិធានការគន្លឹះទី៣ៈ ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព** | | | | |
| **៣.១** | **ចង្កោមសកម្មភាពទី១ៈ ផែនការយុទ្ធសាស្ត្រនៃការកសាងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ២០២៤-២០២៨** | | | |
| | ៣.១.១ | ផែនការយុទ្ធសាស្ត្រនៃការកសាងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ២០២៤-២០២៨ ត្រូវបានរៀបចំ | ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តផ្អែកលើផែនការយុទ្ធសាស្ត្រ | ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តផ្អែកលើផែនការយុទ្ធសាស្ត្រ |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| ៣.២ | ចង្កោមសកម្មភាពទី២៖ ការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម | | | |
| | ៣.២.១ | សេចក្តីណែនាំអំពីការរៀបចំ និងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | សេចក្តីណែនាំអំពីការរៀបចំ និងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់រាជរដ្ឋាភិបាល ត្រូវបានដាក់ឱ្យអនុវត្ត | សេចក្តីណែនាំអំពីការរៀបចំ និងការអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់រាជរដ្ឋាភិបាល ត្រូវបានដាក់ឱ្យអនុវត្ត |
| | ៣.២.២ | ការរៀបចំនិងដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់អង្គភាពនិងមន្ត្រី ដែលមានតួនាទីនិងភារកិច្ចក្នុងការរៀបចំ គាំទ្រ និងអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់៖<br>- រដ្ឋបាលសាធារណៈ<br>- វិស័យអប់រំ និង<br>- សុខាភិបាល | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាព និងមន្ត្រីក្នុងមុខងារគន្លឹះ និងកម្មវិធីលើកទឹកចិត្ត ត្រូវបានដាក់ឱ្យដំណើរការ | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាព និងមន្ត្រីក្នុងមុខងារគន្លឹះ និងកម្មវិធីលើកទឹកចិត្ត ត្រូវបានដាក់ឱ្យដំណើរការ |
| | ៣.២.៣ | ការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់អង្គភាពកម្រិតអគ្គនាយកដ្ឋានដែលមានមុខងារគន្លឹះរបស់ក្រសួង ស្ថាប័ន | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពត្រូវបានរៀបចំ និងកម្មវិធីលើកទឹកចិត្តត្រូវបានដាក់ឱ្យដំណើរការ | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពត្រូវបានរៀបចំ និងកម្មវិធីលើកទឹកចិត្តត្រូវបានដាក់ឱ្យដំណើរការ |
| | ៣.២.៤ | ការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់អង្គភាព និងមន្ត្រីគ្រប់គ្រងអង្គភាព (មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ) | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មគ្រឹះស្ថានអប់រំមូលដ្ឋាន និងមន្ត្រីគ្រប់គ្រងអង្គភាព និងកម្មវិធីលើកទឹកចិត្ត ត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការ | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មគ្រឹះស្ថានអប់រំមូលដ្ឋាន និងមន្ត្រីគ្រប់គ្រងអង្គភាព និងកម្មវិធីលើកទឹកចិត្ត ត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការ |
| | ៣.២.៥ | ការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់អង្គភាពសុខាភិបាលមូលដ្ឋាន និង | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពសុខាភិបាលមូលដ្ឋាន និងមន្ត្រីគ្រប់គ្រងអង្គភាព និងកម្មវិធីលើកទឹកចិត្ត ត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការ | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពសុខាភិបាលមូលដ្ឋាន និងមន្ត្រីគ្រប់គ្រងអង្គភាព និងកម្មវិធីលើកទឹកចិត្ត ត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការ |

| វិធានការគន្លឹះ និងចង្កោមសកម្មភាព | | | | |
|---|---|---|---|---|
| ល.រ | | ពេលវេលាអនុវត្ត និងសូចនាករសមិទ្ធកម្ម | | |
| | | ២០២៤ | ២០២៥ - ២០២៦ | ២០២៧ - ២០២៨ |
| | | មន្ត្រីគ្រប់គ្រងអង្គភាព (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២) | | |
| | ៣.២.៦ | ការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មរបស់អង្គភាពនិងមន្ត្រីដែលមានមុខងារគន្លឹះ៖<br>- គោលនយោបាយ<br>- នីតិកម្ម<br>- ធនធានមនុស្ស<br>- ថវិកា<br>- ត្រួតពិនិត្យនិងវាយតម្លៃ<br>- អធិការកិច្ច និងសវនកម្ម<br>- ការផ្លាស់ប្តូរកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល រួមមាន ការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ ការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការដ្ឋានកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌<br>- សិក្សា និងស្រាវជ្រាវក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពនិងមន្ត្រីក្នុងមុខងារគន្លឹះនិងកម្មវិធីលើកទឹកចិត្ត ត្រូវបានដាក់ឱ្យដំណើរការ | ប្រព័ន្ធវាយតម្លៃសមិទ្ធកម្មអង្គភាពនិងមន្ត្រីក្នុងមុខងារគន្លឹះនិងកម្មវិធីលើកទឹកចិត្ត ត្រូវបានដាក់ឱ្យដំណើរការ |

# ផែនការសកម្មភាព ២០២៤ - ២០២៨
# ដើម្បីអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ
# របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

QR Code សម្រាប់ទាញយកឯកសារ

រៀបចំបោះពុម្ពដោយ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
ខែឧសភា ឆ្នាំ២០២៤